**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ០៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតតំបន់គ្រប់គ្រង និងអភិរក្សដែនបម្រុងសត្វក្រៀល និងសត្វស្លាបផ្សេងទៀត ស្ថិតនៅទីតាំងអន្លង់ព្រីង ស្រុកកំពង់ត្រាច ខេត្តកំពត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខនស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១០

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលដៅ បង្កើតតំបន់គ្រប់គ្រង និងអភិរក្សដែនបម្រុងសត្វក្រៀល និងសត្វស្លាបផ្សេងទៀត ស្ថិតនៅទីតាំងអន្លង់ព្រីង ស្រុកកំពង់ត្រាច ខេត្តកំពត។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលបំណង៖

- ការពារ និងអភិរក្សធនធានសេនេទិចសត្វព្រៃ មច្ឆជាតិ និងរុក្ខជាតិ ពិសេសសត្វក្រៀល និងសត្វស្លាបផ្សេងទៀត ដែលជាប្រភេទជិតផុតពូជ ប្រភេទមានដោយកម្រ ប្រភេទកំពុងទទួលរងគ្រោះថ្នាក់ និងរក្សាលំនឹង មជ្ឈដ្ឋានធម្មជាតិ និងទីជម្រករបស់វា

- ទ្រទ្រង់សកម្មភាពផ្សេងៗ រួមមានការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកទេស ការអប់រំផ្សព្វផ្សាយ បណ្តុះបណ្តាល អភិវឌ្ឍន៍សហគមន៍ និងការអង្កេតតាមដានពីភាពប្រែប្រួលបរិស្ថាន ដែលទាក់ទងនឹងការអភិវឌ្ឍប្រកបដោយនិរន្តរភាព

- ការពារប្រភពចំណី និងថែរក្សាប្រភពទឹក ឲ្យមានប្រក្រតីភាពសម្រាប់ជីវៈចម្រុះដើម្បីធានាឲ្យមាននិរន្តរភាព ប្រព័ន្ធអេកូឡូស៊ី សេដ្ឋកិច្ចសង្គម និងបរិស្ថាន

- ទប់ស្កាត់រាល់ការចូលរុករានទន្រ្ទានកាប់បំផ្លិចបំផ្លាញធនធានធម្មជាតិ ពិសេសការរំលោភយកដីធ្វើកម្មសិទ្ធិ ធ្វើស្រែបង្កា និងសកម្មភាពល្មើសច្បាប់ផ្សេងៗទៀត

- រក្សាលំនឹងមជ្ឈដ្ឋានធម្មជាតិ ដែលជាជម្រកសម្រាប់ការស្នាក់អាស្រ័យសុខសាន្ត និងការបន្តពូជរបស់សត្វព្រៃ មច្ឆជាតិ និងរុក្ខជាតិ

- បម្រើឲ្យគោលដៅអេកូទេសចរណ៍។

## ជំពូកទី២
## ការកំណត់តំបន់

**មាត្រា៣.-**

តំបន់គ្រប់គ្រង និងអភិរក្សដែនបម្រុងសត្វក្រៀល និងសត្វស្លាបផ្សេងទៀតដូចមានចែងក្នុងមាត្រា១ នៃអនុក្រឹត្យនេះ មានផ្ទៃក្រឡា ទំហំ ២១៧ (ពីររយដប់ប្រាំពីរ) ហិកតា ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធ ជាប្រព័ន្ធខ្សែព្រំបិទកំណត់ដោយបណ្តាចំណុចគោល ដែលមាននិយាមការ៖

0 (448534, 1159354); 1 (448141, 1158984); 2 (448049, 1158828); 3 (447989, 1158678); 4 (448464, 1158509); 5 (448652, 1158977); 6 (448735, 1159127); 7 (448022, 1158637); 8 (447986, 1158493); 9 (447784, 1158527); 10 (447708, 1158585); 11 (447696, 1158681); 12 (447570, 1158694); 13 (447586, 1158589); 14 (447644, 1158505); 15 (447735, 1158475); 16 (447825, 1158457); 17 (447830, 1158389); 18 (447847, 1158323); 19 (447879, 1158315);

20 (447862, 1158138); 21 (447876, 1158098); 22 (447670, 1157480); 23 (447661, 1157345); 24 (447692, 1157252); 25 (447757, 1157164); 26 (448312, 1156868); 27 (448536, 1156797); 28 (448861, 1156725); 29 (448884, 1156374); 30 (448826, 1156142); 31 (448961, 1156121); 32 (448977, 1155963); 33 (449010, 1155881); 34 (449051, 1155873); 35 (449070, 1155815); 36 (449111, 1155939); 37 (449490, 1156316); 38 (449502, 1156360); 39 (449450, 1156522); 40 (449371, 1156694); 41 (449327, 1156767); 42 (449212, 1156915); 43 (449161, 1156955); 44 (449082, 1156999); 45 (449045, 1157005); 46 (448993, 1156984); 47 (448748, 1157464); 48 (448673, 1157568); 49 (448575, 1157440); 50 (448590, 1157424); 51 (448502, 1157323); 52 (448469, 1157346); 53 (448442, 1157312); 54 (448327, 1157369); 55 (448229, 1157469); 56 (448187, 1157331); 57 (448197, 1157580); 58 (448226, 1157491); 59 (448268, 1157541); 60 (448248, 1157589); 61 (448291, 1157646); 62 (448247, 1157679); 63 (448286, 1157718); 64 (448472, 1157615); 65 (448498, 1157573); 66 (448591, 1157681); 67 (448467, 1157848); 68 (448537, 1158082); 69 (448528, 1158172); 70 (448446, 1158303); 71 (448431, 1158409); 72 (448440, 1158478);។

**មាត្រា៤.-**

ផ្ទៃក្រឡាតំបន់គ្រប់គ្រង និងអភិរក្សដែនបម្រុងសត្វក្រៀល និងសត្វស្លាបផ្សេងទៀត ដូចមានចែងក្នុងមាត្រា៣ ខាងលើនេះ អាចធ្វើការកែប្រែតាមការចាំបាច់ ដោយផ្អែកលើព័ត៌មានវិទ្យាសាស្ត្រជាមូលដ្ឋាន និងស្ថានភាពជាក់ស្តែងនាពេលអនាគត។

## ជំពូកទី៣
## ការគ្រប់គ្រង

**មាត្រា៥.-**

តំបន់គ្រប់គ្រង និងអភិរក្សដែនបម្រុងសត្វក្រៀល និងសត្វស្លាបផ្សេងទៀត ស្ថិតនៅទីតាំងអន្លង់ព្រីង ស្រុកកំពង់ត្រាច ខេត្តកំពត ត្រូវបានការពារ និងអភិរក្សយ៉ាងហ្មត់ចត់បំផុតដើម្បីធានាឲ្យបានគង់វង្សនូវទីជម្រក និងប្រភពចំណីអាហារសត្វក្រៀល និងសត្វស្លាបផ្សេងទៀត។

តំបន់នេះអាចអនុញ្ញាតឲ្យមានសកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រ ការអង្កេតតាមដាន បម្រើឲ្យគោលដៅអេកូទេសចរណ៍ និងការនេសាទប្រកបដោយនិរន្តរភាព ដោយមិនអនុញ្ញាតឲ្យមានសកម្មភាពប្រើប្រាស់ដែលធ្វើឲ្យរេចរឹល ឬបំផ្លិចបំផ្លាញដល់ជីវៈចម្រុះឡើយ។

**មាត្រា៦.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសមត្ថកិច្ចរៀបចំ និងគ្រប់គ្រងតំបន់គ្រប់គ្រង និងអភិរក្សដែនបម្រុងសត្វក្រៀល និងសត្វស្លាបផ្សេងទៀត ស្ថិតនៅទីតាំង អន្លង់ព្រីង ស្រុកកំពង់ត្រាច ខេត្តកំពត ដោយសហការជាមួយ ក្រសួងពាក់ព័ន្ធ និងរដ្ឋបាលដែនដី ដើម្បីធានានូវការអភិវឌ្ឍធនធានធម្មជាតិ ប្រកបដោយនិរន្តរភាពសម្រាប់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់នោះ។

ដំណើរការនៃការរៀបចំ និង គ្រប់គ្រងតំបន់គ្រប់គ្រង និង អភិរក្សដែនបម្រុងសត្វក្រៀល និង សត្វស្លាបផ្សេងទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០១១

ស្តីពី ការបង្កើតតំបន់គ្រប់គ្រង និងអភិរក្សដែនជម្រកសត្វក្រៀល និងសត្វស្លាបផ្សេងទៀត

ស្ថិតនៅតំបន់អន្លង់ព្រីង ស្រុកកំពង់ត្រាច ខេត្តកំពត

ការាងចំណុចនិយាមកា

| FID | X Proj | Y Proj | Map datum |
|---|---|---|---|
| 0 | 448534. | 1159354. | WGS 84 |
| 1 | 448141. | 1158984. | - |
| 2 | 448049. | 1158828. | - |
| 3 | 447998. | 1158678. | - |
| 4 | 448464. | 1158509. | - |
| 5 | 448652. | 1158977. | - |
| 6 | 448735. | 1159127. | - |
| 7 | 448022. | 1158637. | - |
| 8 | 447986. | 1158493. | - |
| 9 | 447784. | 1158527. | - |
| 10 | 447708. | 1158585. | - |
| 11 | 447696. | 1158681. | - |
| 12 | 447570. | 1158694. | - |
| 13 | 447586. | 1158589. | - |
| 14 | 447644. | 1158505. | - |
| 15 | 447735. | 1158475. | - |
| 16 | 447825. | 1158457. | - |
| 17 | 447830. | 1158389. | - |
| 18 | 447847. | 1158323. | - |
| 19 | 447879. | 1158315. | - |
| 20 | 447862. | 1158138. | - |
| 21 | 447876. | 1158098. | - |
| 22 | 447670. | 1157480. | - |
| 23 | 447661. | 1157345. | - |
| 24 | 447692. | 1157252. | - |
| 25 | 447757. | 1157164. | - |
| 26 | 448312. | 1156868. | - |
| 27 | 448536. | 1156797. | - |
| 28 | 448861. | 1156725. | - |
| 29 | 448884. | 1156374. | - |
| 30 | 448826. | 1156142. | - |
| 31 | 448961. | 1156121. | - |
| 32 | 448977. | 1155963. | - |
| 33 | 449010. | 1155881. | - |
| 34 | 449051. | 1155873. | - |
| 35 | 449070. | 1155815. | - |
| 36 | 449111. | 1155939. | - |
| 37 | 449490. | 1156316. | - |
| 38 | 449502. | 1156360. | - |
| 39 | 449450. | 1156522. | - |
| 40 | 449371. | 1156694. | - |
| 41 | 449327. | 1156767. | - |
| 42 | 449212. | 1156915. | - |
| 43 | 449161. | 1156955. | - |
| 44 | 449082. | 1156999. | - |
| 45 | 449045. | 1157005. | - |
| 46 | 448993. | 1156984. | - |
| 47 | 448748. | 1157464. | - |
| 48 | 448673. | 1157568. | - |
| 49 | 448575. | 1157440. | - |
| 50 | 448590. | 1157424. | - |
| 51 | 448502. | 1157323. | - |
| 52 | 448469. | 1157346. | - |
| 53 | 448442. | 1157312. | - |
| 54 | 448317. | 1157369. | - |
| 55 | 448219. | 1157469. | - |
| 56 | 448187. | 1157531. | - |
| 57 | 448197. | 1157580. | - |
| 58 | 448216. | 1157491. | - |
| 59 | 448268. | 1157541. | - |
| 60 | 448248. | 1157589. | - |
| 61 | 448291. | 1157646. | - |
| 62 | 448247. | 1157679. | - |
| 63 | 448286. | 1157718. | - |
| 64 | 448472. | 1157615. | - |
| 65 | 448498. | 1157573. | - |
| 66 | 448591. | 1157681. | - |
| 67 | 448467. | 1157848. | - |
| 68 | 448537. | 1158082. | - |
| 69 | 448518. | 1158172. | - |
| 70 | 448416. | 1158303. | - |
| 71 | 448431. | 1158409. | - |
| 72 | 448440. | 1158478. | - |




Datum :WGS_1984_UTM_Zone_48N
Projection: Transverse_Mercator




សញ្ញាសម្គាល់

- ● ទីតាំងរកចំណីរបស់សត្វក្រៀល
- ● ចំណុចនិយាមកា
- ព្រំប្រទល់តំបន់គ្រប់គ្រង និងអភិរក្ស
- ក្រឡាផ្ទៃដីសរុប : A+B=២១៧ ហិកតា
- A ទីតាំងទី១ ទំហំ ៣៣ ហិកតា
- B ទីតាំងទី២ ទំហំ ១៨៤ ហិកតា
- ព្រំប្រទល់ប្រទេស
- ព្រំប្រទល់ឃុំ
- ផ្លូវទឹក
- ផ្លូវ
- ស្ពានដែក (ផ្លូវ)
- [illegible], ព្រៃកោងកាង
- វាលស្រែ, វាលស្រែលិចទឹក




បានឃើញ និង ឯកភាព

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១០

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ / រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អ៊ឹម ឈុនលឹម

ទំហំផ្ទៃដីតំបន់ គ្រប់គ្រង និងអភិរក្ស បានមកពីទិន្នន័យនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ (LMAP) ដែលធ្វើ ម.ដ.ន.ស ខេត្តកំពត